**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ...៤៨៧...ឥ.វណ....ប.ស្ថ

ថ្ងៃ ចន្ទ ១៣កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងបរិស្ថានសម្រាប់ ឆ្នាំ២០២៣

ក្រសួងបរិស្ថាន មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា នៅឆ្នាំ២០២៣ នេះ ក្រសួងបរិស្ថានមានការប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងបរិស្ថាន ចំនួន **៣១កន្លែង**។ ចំពោះព័ត៌មាន និងលក្ខខណ្ឌពាក់ព័ន្ធនឹងការប្រឡងជ្រើសរើស មានដូចជម្រាបជូនខាងក្រោមៈ

**១ . អង្គភាពដែលត្រូវបម្រើការងារ**

**១.១. ទីស្តីការក្រសួង ក្របខ័ណ្ឌប្រភេទ "ក" ចំនួន ១៧ កន្លែង**

| ល.រ | អង្គភាព | ចំនួន | មុខជំនាញ |
|---|---|---|---|
| **I. អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ចំនួន ០២ កន្លែង** | | | |
| ១ | នាយកដ្ឋានតំបន់បេតិកភណ្ឌ | ០១ | បុរាណវិទ្យា និងភូគព្ភសាស្ត្រ |
| ២ | នាយកដ្ឋានទេសចរណ៍ធម្មជាតិ | ០១ | គ្រប់គ្រងទេសចរណ៍និងបដិសណ្ឋារកិច្ច, នីតិសាស្ត្រ, គណនេយ្យនិងហិរញ្ញវត្ថុ |
| **II. អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ចំនួន ០២ កន្លែង** | | | |
| ១ | នាយកដ្ឋានរង្វាន់និងលើកទឹកចិត្ត | ០២ | គណនេយ្យ, វិទ្យាសាស្ត្រកុំព្យូទ័រ, ព័ត៌មានវិទ្យា, នីតិសាស្ត្រ |
| **III. អគ្គនាយកដ្ឋានគាំពារបរិស្ថាន ចំនួន ០២ កន្លែង** | | | |
| ១ | នាយកដ្ឋានគ្រប់គ្រងសំណល់រឹង | ០១ | វិទ្យាសាស្ត្របរិស្ថាន, គីមីឧស្សាហកម្ម និងចំណីអាហារ, វិស្វកម្មគីមី និងវិទ្យាសាស្ត្រអាហារ |
| ២ | នាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ | ០១ | នីតិសាស្ត្រ |
| **IV. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ចំនួន ០៥ កន្លែង** | | | |
| ១ | នាយកដ្ឋានធនធានមនុស្ស | ០១ | ព័ត៌មានវិទ្យា |

| | | | |
|---|---|---|---|
| ២ | នាយកដ្ឋានផែនការ ថវិកា និងសហប្រតិបត្តិការ | ០១ | ទំនាក់ទំនងអន្តរជាតិ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, សេដ្ឋកិច្ច ព័ត៌មាន |
| ៣ | នាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | ០១ | ធនាគារនិងហិរញ្ញវត្ថុ, គណនេយ្យ, គ្រប់គ្រងសាធារណៈ |
| ៤ | នាយកដ្ឋានហិរញ្ញវត្ថុនិងគណនេយ្យ | ០១ | ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ |
| ៥ | លេខាធិការដ្ឋាន នៃនាយកដ្ឋានរដ្ឋបាល | ០១ | រដ្ឋបាលសាធារណៈ, នីតិសាធារណៈ, ព័ត៌មានវិទ្យា, ធនាគារនិងហិរញ្ញវត្ថុ, គណនេយ្យ, ភាសាអង់គ្លេស, គ្រប់គ្រង |
| **V. អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ចំនួន ០៣ កន្លែង** | | | |
| ១ | នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ | ០២ | គ្រប់គ្រង, គណនេយ្យនិងហិរញ្ញវត្ថុ, វិទ្យាសាស្ត្រកុំព្យូទ័រ, នីតិសាស្ត្រ, វិទ្យាសាស្ត្របរិស្ថាន, សេដ្ឋកិច្ច |
| ២ | នាយកដ្ឋានអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ | ០១ | គ្រប់គ្រង, គណនេយ្យនិងហិរញ្ញវត្ថុ, វិទ្យាសាស្ត្រកុំព្យូទ័រ, នីតិសាស្ត្រ, វិទ្យាសាស្ត្របរិស្ថាន, សេដ្ឋកិច្ច |
| **VI. អគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ ចំនួន ០៣ កន្លែង** | | | |
| ១ | នាយកដ្ឋានសេដ្ឋកិច្ចបៃតង | ០១ | វិទ្យាសាស្ត្រសេដ្ឋកិច្ច, និរន្តរភាពទីក្រុង ថាមពល |
| ២ | នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ០១ | វិទ្យាសាស្ត្របរិស្ថាន, បច្ចេកវិទ្យា, នវានុវត្តន៍ |
| **VII. នាយកដ្ឋានសវនកម្មផ្ទៃក្នុង** | | ០១ | គណនេយ្យនិងហិរញ្ញវត្ថុ, នីតិសាស្ត្រ |

### ១.២. មន្ទីរបរិស្ថានខេត្ត ក្របខ័ណ្ឌប្រភេទ "ក" ចំនួន ១៤ កន្លែង

| | | | |
|---|---|---|---|
| ១ | មន្ទីរបរិស្ថានខេត្តកំពង់ចាម | ០១ | វិទ្យាសាស្ត្របរិស្ថាន, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ, គណនេយ្យ និងហិរញ្ញវត្ថុ |
| ២ | មន្ទីរបរិស្ថានខេត្តសៀមរាប | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ៣ | មន្ទីរបរិស្ថានខេត្តពោធិ៍សាត់ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ៤ | មន្ទីរបរិស្ថានខេត្តបាត់ដំបង | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, គ្រប់គ្រងធនធានធម្មជាតិ |

| | | | |
|---|---|---|---|
| ៥ | មន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, គ្រប់គ្រងធនធានធម្មជាតិ, គណនេយ្យនិងហិរញ្ញវត្ថុ, ព័ត៌មានវិទ្យា, រដ្ឋបាលសាធារណៈ |
| ៦ | មន្ទីរបរិស្ថានខេត្តព្រះសីហនុ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, គ្រប់គ្រងធនធានធម្មជាតិ |
| ៧ | មន្ទីរបរិស្ថានខេត្តកំពត | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, គ្រប់គ្រងធនធានធម្មជាតិ |
| ៨ | មន្ទីរបរិស្ថានខេត្តព្រៃវែង | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ៩ | មន្ទីរបរិស្ថានខេត្តស្វាយរៀង | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ១០ | មន្ទីរបរិស្ថានខេត្តតាកែវ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, គ្រប់គ្រងធនធានធម្មជាតិ |
| ១១ | មន្ទីរបរិស្ថានខេត្តរតនគិរី | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ១២ | មន្ទីរបរិស្ថានខេត្តកោះកុង | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គណនេយ្យនិងហិរញ្ញវត្ថុ, គ្រប់គ្រងធនធានធម្មជាតិ |
| ១៣ | មន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |
| ១៤ | មន្ទីរបរិស្ថានខេត្តព្រះវិហារ | ០១ | វិទ្យាសាស្ត្របរិស្ថាន, វិទ្យាសាស្ត្រព្រៃឈើ, ព័ត៌មានវិទ្យា, គ្រប់គ្រងធនធានធម្មជាតិ |

## ២. លក្ខខណ្ឌសម្រាប់ជ្រើសរើស

បេក្ខជន បេក្ខនារី ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១. ត្រូវមានសញ្ជាតិខ្មែរ។

២. បេក្ខជន បេក្ខនារី ត្រូវមានសញ្ញាបត្រថ្នាក់ **បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល** និងមានអាយុមិនឱ្យលើសពី**៣៥ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)។

៣. បេក្ខជន បេក្ខនារី ត្រូវមានសញ្ញាបត្រថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល** ត្រូវមានអាយុមិនឱ្យលើសពី**៤០ឆ្នាំ** (គិតត្រឹមថ្ងៃប្រឡង)។

៤.បេក្ខជន បេក្ខនារី មានសញ្ញាបត្រថ្នាក់ **បណ្ឌិត ឬសញ្ញាបត្រសមមូល** ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។

## ៣. វិញ្ញាសាប្រឡង

-វិញ្ញាសា ចំណេះដឹងទូទៅ (រយៈពេល ០២ម៉ោង)

-វិញ្ញាសា ជំនាញឯកទេសបរិស្ថាន (រយៈពេល ០២ម៉ោង)

-វិញ្ញាសា ភាសាអង់គ្លេស (រយៈពេល ០១ម៉ោង ៣០នាទី)

## ៤. កាលបរិច្ឆេទប្រឡង

-ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៧:០០នាទីព្រឹក

## ៥. មណ្ឌលប្រឡង

-ទីស្តីការក្រសួងបរិស្ថាន (សាលប្រជុំ ម៉ុក ម៉ារ៉េត)

## ៦ .ការទទួលពាក្យ

ចាប់ផ្តើមទទួលពាក្យសុំសិទ្ធិប្រឡងចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រៀងរាល់ម៉ោងធ្វើការពេលព្រឹក ចាប់ពីម៉ោង ០៨:០០នាទីព្រឹក ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី នៅនាយកដ្ឋានធនធានមនុស្ស ដែលមានទីតាំងស្ថិតនៅអាគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និង នៅមន្ទីរបរិស្ថានរាជធានី-ខេត្ត ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣។

## ៧. បេក្ខជន បេក្ខនារី ត្រូវបំពេញសំណុំលិខិតក្នុងការដាក់ពាក្យប្រឡងរួមមាន៖

| | |
|---|---|
| ១.ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ច្បាប់ |
| ២.រូបថតថ្មី ថតចំពីមុខ (៤ x ៦) | ចំនួន០២សន្លឹក |
| ៣.សលាកបត្រឯកត្តជន | ចំនួន ០២ច្បាប់ |
| ៤.សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ជាផ្លូវការ | ចំនួន ០១ច្បាប់ |
| ៥.ជីវប្រវត្តិសង្ខេបមានបិទរូបថត(៤ x ៦) | ចំនួន ០១ច្បាប់ |
| ៦.បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០២ច្បាប់ |
| ៧.កិច្ចសន្យាបម្រើការងារក្រសួង | ចំនួន ០១ច្បាប់ |
| ៨.សេចក្តីចម្លងសំបុត្រកំណើត | ចំនួន ០១ ច្បាប់ |
| ៩.ថតចម្លងសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ | ចំនួន ០១ ច្បាប់ |

១០.ជនពិការ ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់ជាអាទិភាព។

<u>បញ្ជាក់៖</u>

- **បេក្ខជន បេក្ខនារី** ដែលមានបំណងដាក់ពាក្យសុំប្រឡង សូមចូលទៅគេហទំព័រ www.moe.gov.kh ដើម្បីទាញយកពាក្យសុំសិទ្ធិប្រឡង។
- **បេក្ខជន បេក្ខនារី** ត្រូវមកដាក់ពាក្យសុំសិទ្ធិប្រឡងដោយខ្លួនឯងផ្ទាល់ និងបង់កម្រៃសុំសិទ្ធិប្រឡង ចំនួន ៤០,០០០រៀល (បួនម៉ឺនរៀល) ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណ។
- ចំពោះ **បេក្ខជន បេក្ខនារី** ជ្រើសរើសយកប៉ុស្តិ៍នៅទីស្តីការក្រសួងបរិស្ថាន ត្រូវដាក់ពាក្យនៅទីស្តីការក្រសួងបរិស្ថានដោយផ្ទាល់ខ្លួន។

- ចំពោះ **បេក្ខជន បេក្ខនារី** ជ្រើសរើសយកប៉ុស្តិ៍នៅមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវមានអាសយដ្ឋានស្នាក់នៅក្នុងខេត្តសាមីផ្ទាល់ និងអាចដាក់ពាក្យនៅមន្ទីរបរិស្ថានរាជធានី-ខេត្តសាមី ឬនៅទីស្តីការក្រសួងបរិស្ថានដោយផ្ទាល់។
- **បេក្ខជន បេក្ខនារី** ត្រូវបំពេញបែបបទសុំសិទ្ធិប្រឡងដោយចុះហត្ថលេខាផ្ទាល់ខ្លួន។
- **បេក្ខជន បេក្ខនារី** ដែលប្រឡងជាប់ត្រូវបំពេញការងារនៅក្នុងអង្គភាពរយៈពេល ៥ឆ្នាំ ទើបអាចស្នើសុំការផ្ទេរ និងការផ្លាស់ប្តូរកន្លែងធ្វើការ។
- **បេក្ខជន បេក្ខនារី** ត្រូវមានលិខិតបញ្ជាក់កិរិយាមាយាទពី ឃុំ-សង្កាត់ (ក្រោយប្រឡងជាប់)។
- **បេក្ខជន បេក្ខនារី** ត្រូវមានលិខិតបញ្ជាក់សុខភាពនិងកាយសម្បទាពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (ក្រោយប្រឡងជាប់)។
- **បេក្ខជន បេក្ខនារី** ត្រូវមានលិខិតថ្កោលទោសភ្ជាប់មកជាមួយ (ក្រោយប្រឡងជាប់)។

## ៨. ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានលម្អិត សូមមកទាក់ទងនៅនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន រៀងរាល់ម៉ោងធ្វើការ ឬទំនាក់ទំនងតាមទូរស័ព្ទលេខ៖ ០៨៩ ៩៦២ ៣១៣/ ០១២ ៥១៧ ៣៧៦ / ០៨៧ ៣៧៧ ៧៤៤ / ០៩៧ ៩៤២ ៧២៧ ៩។

អាស្រ័យហេតុនេះ សាធារណជនទាំងអស់ជ្រាបជាព័ត៌មាន៕

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន
- សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន
- ឯកសារ កាលប្បវត្តិ